# តម្រូវការនៃការចាក់ថ្នាំបង្ការរោគ
## សម្រាប់ការចូលរៀននៅសាលារបស់រដ្ឋផិនស៊ីលវេនីញ៉ា

### សម្រាប់ការចូលរៀនគ្រប់ថ្នាក់ទាំងអស់ ក្មេងត្រូវការការចាក់ថ្នាំបង្ការរោគដូចតទៅ៖





- តេតាណុស ខាន់ស្លាក់ និង ក្អកមាន់ ៤ ដង* (១ ដង នៅពេល ឬក្រោយពេលមានអាយុ ៤ ឆ្នាំ)
- រោគស្វិតសរសៃ ៤ ដង (លើកទី ៤ នៅពេល ឬក្រោយពេលមានអាយុ ៤ ឆ្នាំ ហើយយ៉ាងហោចណាស់ ៦ ខែ ក្រោយពីការចាក់ពីលើកមុន)**
- កញ្ជ្រិល សាលាទែន ស្អូច ២ ដង***
- រោគហើមថ្លើមប្រភេទ B ៣ ដង
- អុតស្វាយ ២ ដង ឬ មានភស្តុតាងថាធ្លាប់កើតរួចហើយ

**តាមធម្មតា ចាក់ថ្នាំ តេតាណុស ខាន់ស្លាក់ និង ក្អកមាន់ (DTP or DTaP) រួមគ្នា ឬបើសិនជាគ្មានបញ្ហាសុខភាព ចាក់ថ្នាំ DT ឬ Td*
*** មិនត្រូវការចាក់ថ្នាំលើកទីបួនទេ បើសិនជាលើកទីបីចាក់នៅពេលមានអាយុ ៤ ឆ្នាំ ឬលើសពីនេះ ហើយតិចជាង ៦ ខែ ក្រោយពីការចាក់ពីលើកមុន*

****តាមធម្មតា ចាក់ថ្នាំ កញ្ជ្រិល សាលាទែន ស្អូច (MMR)រួមគ្នា*

**នៅថ្ងៃចូលរៀនដំបូង** លុះត្រាតែមានការលើកលែងដោយសារក្មេងមានបញ្ហាសុខភាព ឬ សាសនា/ទស្សនៈ ក្មេងត្រូវតែមានការចាក់ថ្នាំបង្ការរោគខាងលើនេះ យ៉ាងហោចណាស់មួយ បើមិនដូច្នោះទេគេអាចមិនឲ្យសិស្សចូលរៀន។

- បើសិនជាក្មេងមិនបានចាក់ថ្នាំបង្ការរោគគ្រប់ចំនួនដូចខាងលើនេះ ត្រូវការចាក់បន្ថែម ហើយការចាក់ថ្នាំបន្ទាប់ទៀតនោះត្រូវតាមលក្ខណៈរបស់ពេទ្យ ក្មេងត្រូវតែចាក់ថ្នាំនោះក្នុងកំឡុងពេលប្រាំថ្ងៃ នៃថ្ងៃចូលរៀនដំបូង បើមិនដូច្នោះទេ គេអាចមិនឲ្យសិស្សចូលរៀន។ បើសិនជាការចាក់ថ្នាំបន្ទាប់ទៀត មិនមែនជាការចាក់ចុងក្រោយបង្អស់ក្នុងការចាក់ថ្នាំឲ្យគ្រប់ចំនួនទេ ក្មេងត្រូវផ្តល់គម្រោងការចាក់ថ្នាំ (ប័ណ្ណពណ៌ ក្រហម ស) ក្នុងកំឡុងពេលប្រាំថ្ងៃ នៃថ្ងៃចូលរៀនដំបូង សម្រាប់តម្រូវការនៃការចាក់ថ្នាំបង្ការរោគ បើមិនដូច្នោះទេ គេអាចមិនឲ្យសិស្សចូលរៀន។
- បើសិនជាក្មេងមិនបានចាក់ថ្នាំបង្ការរោគគ្រប់ចំនួនទាំងអស់ដូចខាងលើនេះ ត្រូវការចាក់បន្ថែម ហើយការចាក់ថ្នាំបន្ទាប់ទៀតនោះមិនត្រូវតាមលក្ខណៈរបស់ពេទ្យ ក្មេងត្រូវផ្តល់គម្រោងការចាក់ថ្នាំ (ប័ណ្ណពណ៌ ក្រហម ស) ក្នុងកំឡុងពេលប្រាំថ្ងៃ នៃថ្ងៃចូលរៀនដំបូង សម្រាប់តម្រូវការនៃការចាក់ថ្នាំបង្ការរោគ បើមិនដូច្នោះទេ គេអាចមិនឲ្យសិស្សចូលរៀន។
- ត្រូវធ្វើតាមផែនការសុខភាព បើមិនដូច្នោះទេ គេអាចមិនឲ្យសិស្សចូលរៀន។

### សម្រាប់ការចូលរៀនថ្នាក់ទី៧៖

- តេតាណុស ខាន់ស្លាក់ និង ក្អកមាន់ (Tdap) ១ ដង នៅថ្ងៃចូលរៀនថ្នាក់ទី៧ ដំបូង។
- ថ្នាំបង្ការរោគរលាកស្រោមខួរ (MCV) ១ ដង នៅថ្ងៃចូលរៀនថ្នាក់ទី៧ ដំបូង។

**នៅថ្ងៃចូលរៀនថ្នាក់ទី៧ ដំបូង**

លុះត្រាតែមានការលើកលែងដោយសារក្មេងមានបញ្ហាសុខភាព ឬ សាសនា/ទស្សនៈ ក្មេងត្រូវតែមានការចាក់ថ្នាំបង្ការរោគដូចខាងលើនេះ បើមិនដូច្នោះទេ គេអាចមិនអនុញ្ញាតឲ្យក្មេងចូលរៀន។

### សម្រាប់ការចូលរៀនថ្នាក់ទី១២៖

- ថ្នាំបង្ការរោគរលាកស្រោមខួរ (MCV) ១ ដង នៅថ្ងៃចូលរៀនថ្នាក់ទី១២ ដំបូង។ បើសិនជាបានចាក់ថ្នាំនៅពេលមានអាយុ ១៦ ឆ្នាំ ឬលើសពីនេះ អាចចាត់ទុកថាជាការចាក់ថ្នាំសម្រាប់ថ្នាក់ទី១២។

**នៅថ្ងៃចូលរៀនថ្នាក់ទី១២ ដំបូង**

លុះត្រាតែមានការលើកលែងដោយសារក្មេងមានបញ្ហាសុខភាព ឬ សាសនា/ទស្សនៈ ក្មេងត្រូវតែមានការចាក់ថ្នាំបង្ការរោគដូចខាងលើនេះ បើមិនដូច្នោះទេ គេអាចមិនអនុញ្ញាតឲ្យក្មេងចូលរៀន។

តម្រូវការនៃការចាក់ថ្នាំបង្ការរោគសម្រាប់ការចូលរៀន ថ្នាក់ទី ៧ និងថ្នាក់ទី១២ តម្រូវឲ្យមានជាបន្តសម្រាប់ឆ្នាំសិក្សាក្រោយៗ។

តម្រូវការទាំងនេះ អនុញ្ញាតឲ្យមានការលើកលែងដូចតទៅ៖ មូលហេតុនៃសុខភាព ជំនឿសាសនា ឬ ទស្សនៈ/ជំនឿខ្លាំងក្លាលើសីលធម៌។ ទោះជាកូនលោកអ្នកមានការលើកលែងពីការចាក់ថ្នាំបង្ការរោគក៏ដោយ គេអាចមិនឲ្យកូនលោកអ្នកមករៀន នៅពេលណាមានការឆ្លងរោគរាលដាលនៃរោគដែលអាចចាក់ថ្នាំការពារបាន។

តម្រូវការនៃការចាក់ថ្នាំបង្ការរោគសម្រាប់សាលារបស់រដ្ឋផិនស៊ីលវេនញ៉ា មាននៅក្នុងមាត្រាលេខ 28 Pa.CODE CH.23 (ការចាក់ថ្នាំបង្ការរោគសម្រាប់សាលា)។ សូមទាក់ទងក្រុមហ៊ុនផ្តល់សេវាសុខភាពរបស់លោកអ្នក ឬ ទូរស័ព្ទទៅលេខ 1-877-PA-HEALTH ដើម្បីជ្រាបព័ត៌មានបន្ថែម។

pennsylvania
DEPARTMENT OF HEALTH